# រ៉ូយ៉ាល់ លេខេ ម.ក.

របាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ
3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2023
និង
របាយការណ៍របស់សវនករឯករាជ្យ
ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | រ៉ូយ៉ាល់ រេលវេ ម.ក. | |
| លេខបញ្ជីពាណិជ្ជកម្ម | 00018504 | |
| ទីស្នាក់ការចុះបញ្ជី | ស្ថានីយ៍រថភ្លើងភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី<br>សង្កាត់ស្រះចក ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)<br>អ្នកឧកញ៉ា គិត ម៉េង | |
| ក្រុមប្រឹក្សាភិបាល | អ្នកឧកញ៉ា គិត ម៉េង | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Raymond Thornton Yager | អភិបាល |
| | លោក William Mark Hanna | អភិបាល |
| | លោក Paul Clements | អភិបាល |
| | លោក លន់ យ៉េង | អភិបាលឯករាជ្យ |
| អ្នកគ្រប់គ្រង | លោក John Guiry | នាយកប្រតិបត្តិ |
| | លោកស្រី តូច សុធីតា | ប្រធានផ្នែកហិរញ្ញវត្ថុ |
| គណៈកម្មាធិការសវនកម្ម<br>និងហានិភ័យ | លោក លន់ យ៉េង | ប្រធាន |
| | លោក Paul Clements | អភិបាល |
| | លោក William Mark Hanna | អភិបាល |
| គណកម្មាធិការតែងតាំង<br>និងលាភការ | លោក William Mark Hanna | ប្រធាន |
| | លោក Paul Clements | អភិបាល |
| | លោក Raymond Thornton Yager | អភិបាល |
| ធនាគារិកចម្បង | ធនាគារ រីង (ខេមបូឌា) ម.ក | |
| សវនករ | ខេភីអឹមជី ខេមបូឌា | |

**រ៉ូយ៉ាល់ រេលវេ ម.ក.**

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 5 |
| 2. | របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 6 – 8 |
| 3. | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 9 – 10 |
| 4. | របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ សង្ខេបចន្លោះពេល | 11 |
| 5. | របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 12 |
| 6. | របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 13 – 14 |
| 7. | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 15 – 46 |

**ROYAL RAILWAY PLC.**
Central Railway Station, Sangkat Sras Chork, Daun Penh, Phnom Penh, Cambodia
T +885 23 992 379
F +885 23 992 353
www.royal-railway.com

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល("អភិបាល") នៃរ៉ូយ៉ាល់ រេលវេ ម.ក. ("ក្រុមហ៊ុន") សូមធ្វើការដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺពាក់ព័ន្ធនឹងសេវាកម្មផ្លូវដែក ដែលរួមមានសេវាកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមផ្លូវដែក ព្រមទាំងផ្តល់ជូននូវសេវាដឹកជញ្ជូនដោយមធ្យោបាយផ្សេងទៀត ក្នុងករណីដែលការដឹកជញ្ជូនតាមរថភ្លើងមិនអាចប្រព្រឹត្តិទៅបាន និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកនិងគ្រឿងបរិក្ខារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។ សូមមើលទំព័រទី11។

## ភាគលាភ

ពុំមានការប្រកាសបែងចែក ឬទូទាត់ភាគលាភនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភនាកាលបរិច្ឆេទនៃរបាយការណ៍នេះដែល។

## ដើមទុន

ពុំមានការផ្លាស់ប្តូររចនាសម្ព័ន្ធការកាន់កាប់ដើមទុនក្នុងអំឡុងការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់នេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទសនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## របាយការណ៍ លេខាធិការ ម.ក.

### ការខាតបង់ដែលបានរំពឹងទុកទៅលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីធ្វើឲ្យប្រាកដថា សកម្មភាពផ្សេងៗត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

### ទ្រព្យសកម្ម

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឲ្យប្រាកដថា បណ្តាទ្រព្យសកម្មលើកលែងបំណុល ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្ម តាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលបានរំពឹងទុកថាអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

### វិធីសាស្រ្តនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងបានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានស្រាប់ ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការដាក់បញ្ចាំលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង
- លើកលែងតែការបង្ហាញនៅក្នុងកំណត់សម្គាល់ 24 នៃរបាយការណ៍ហិរញ្ញវត្ថុ ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុន ដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងកាលបរិច្ឆេទ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលនឹងបង្កឲ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់នោះឡើយ។

# រ៉ូយ៉ាល់ គ្រុបភ្នំពេញ ម.ក.

## ការផ្លាស់ប្តូរនៃកាលៈទេសៈ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរៀបរាប់នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទរាយការណ៍មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលយល់ឃើញថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *តួនាទី* |
|---|---|
| អ្នកឧកញ៉ា គិត ម៉េង | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Raymond Thornton Yager | អភិបាល |
| លោក William Mark Hanna | អភិបាល |
| លោក Paul Clements | អភិបាល |
| លោក លន់ យ៉េង | អភិបាល |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ ពុំមានអភិបាលណាមួយកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល ក្រៅពីអ្នកឧកញ៉ា គិត ម៉េង ដែលជាប្រធានក្រុមប្រឹក្សាភិបាលមានកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ផង និងដោយប្រយោលតាមរយៈក្រុមហ៊ុនអ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)។

## រ៉ូយ៉ាល់ គ្រុប ម.ក.

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាងដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ បានផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃឡើយ។

នៅក្នុងអំឡុងការិយបរិច្ឆេទ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលមានអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះឡើយ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែមីនា ឆ្នាំ2023 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ដូចបានបង្ហាញនៅទំព័រទី 9 ដល់ទី46 ត្រូវបានរៀបចំឡើងជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ("ស.គ.អ.ក 34")*។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាន និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយស.គ.អ.ក 34 ឬប្រសិនបើមានវៀចចាកពីការបង្ហាញព័ត៌មានដ៏សមស្រប គឺត្រូវធ្វើឲ្យប្រាកដថា ការវៀចចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែវាមានភាពមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតបាន។
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្តីសម្រេច និងសកម្មភាពទាំងឡាយធ្វើឡើងដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងសេចក្តីសម្រេចទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

## រ៉ូយ៉ាល់ រេលវេ ម.ក.

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល(ត)

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវក្នុងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ (រួមទាំងភាពច្បាស់លាស់នៃបញ្ជីនេះ នៅគ្រប់ពេលវេលា) ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រូវធានាថា បញ្ជីគណនេយ្យបានអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាលបានអះអាងថា គណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ខ្ញុំបាទ ជាតំណាងឲ្យក្រុមប្រឹក្សាភិបាលនៃ រ៉ូយ៉ាល់ រេលវេ ម.ក. សូមជូនមតិថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយត្រូវបានរៀបចំឡើងគ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស.គ.អ.ក 34 "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល"។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
រ៉ូយ៉ាល់ រេលវេ ម.ក.
ROYAL RAILWAY PLC.
KINGDOM OF CAMBODIA

អ្នកឧកញ៉ា គិត ម៉េង
*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី15 ខែឧសភា ឆ្នាំ2023

KPMG Cambodia Ltd
GIA Tower, Sopheak Mongkul Street, Phum 14
Sangkat Tonle Bassac, Khan Chamkar Mon
Phnom Penh, Cambodia
+855 (17) 666 537 / +855 (81) 533 999 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ជូនចំពោះភាគទុនិករបស់ រ៉ូយ៉ាល់ រេលវេ ម.ក.

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2023 របស់ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ ម.ក. ហៅកាត់ថា ("ក្រុមហ៊ុន") ដូចបានបង្ហាញនៅទំព័រទី 9 ដល់ទី46 ជារួមហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល") ដែលរួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទីថ្ងៃទី31 ខែមីនា ឆ្នាំ2023
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023
- របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023
- របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023 និង
- កំណត់សម្គាល់ពន្យល់ផ្សេងៗទៀតទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *"របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល"*។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

## *វិសាលភាពនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចការងារត្រួតពិនិត្យលេខ 2410 ស្តីពី"*ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*"។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មានជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ ហើយធ្វើការវិភាគ និងអនុវត្តនូវនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានវិសាលភាពតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ ការត្រួតពិនិត្យមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាជាសារវន្តទាំងឡាយ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មនោះឡើយ។ ហេតុដូច្នេះយើងខ្ញុំ មិនបញ្ចេញមតិសវនកម្មនោះទេ។

## *ការទាញចំណាប់អារម្មណ៍លើបញ្ហា*

យើងខ្ញុំ សូមធ្វើការទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់ 24.1 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលបញ្ជាក់អំពីកម្រៃសម្បទានត្រូវបង់ទៅរាជរដ្ឋាភិបាលកម្ពុជា តាមកិច្ចព្រមព្រៀងសម្បទានដែលមានស្រាប់ សម្រាប់ការប្រើប្រាស់ទ្រព្យសម្បទាន ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទាន។ អ្នកគ្រប់គ្រងរបស់ ក្រុមហ៊ុនបានធ្វើការវាយតម្លៃលើកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងសម្បទានដែលមានស្រាប់ ហើយជឿជាក់ថា កាតព្វកិច្ចក្នុងការទូទាត់ថ្លៃសម្បទាននេះពុំទាន់មានប្រសិទ្ធភាពនៅឡើយទេ។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនកំពុងបន្តការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា ទៅលើវិសោធនកម្មកិច្ចព្រមព្រៀងសម្បទានថ្មី។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនជឿជាក់ថាចំនួន និងពេលវេលានៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចនៅមិនទាន់អាចប៉ាន់ស្មានដោយជឿជាក់បាន ដោយសារតែកាលបរិច្ឆេទមានប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទានមិនត្រូវបានកំណត់នៅឡើយ គិតត្រឹមកាលបរិច្ឆេទរាយការណ៍នេះ។ លទ្ធផលចុងក្រោយនៃបញ្ហានេះ គឺមានលក្ខណៈមិនប្រាកដប្រជា អាស្រ័យហេតុនេះ ពុំមានបំណុលសំវិធានធនណាមួយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលទេ។

## *បញ្ហាផ្សេងៗ*

យើងខ្ញុំ សូមធ្វើការទាញចំណាប់អារម្មណ៍ថា យើងខ្ញុំមិនបានត្រួតពិនិត្យទៅលើរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022 និងកំណត់សម្គាល់ពាក់ព័ន្ធនឹងព័ត៌មានពន្យល់ផ្សេងៗ ដូច្នេះយើងខ្ញុំពុំផ្តល់ការសន្និដ្ឋាន ឬអំណះអំណាងណាមួយទៅលើព័ត៌មានដែលបានរៀបរាប់ខាងលើនោះឡើយ។

KPMG

## *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្ត ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"* នោះឡើយ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

**តាំង យុកហ្វុង**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី15 ខែឧសភា ឆ្នាំ2023

# វីង ហ៊ាល់ អេលអេ ម.ក.

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី31 ខែមីនា ឆ្នាំ2023

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 ដុល្លារអាមេរិក | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 ពាន់រៀល (កំណត់សម្គាល់ 4) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | 5 | 22,562,527 | 91,468,484 | 23,981,297 | 98,731,000 |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | 6 | 2,766,765 | 11,216,465 | 2,370,718 | 9,760,246 |
| សន្និធិ | 7 | 283,141 | 1,147,854 | 214,835 | 884,476 |
| | | 25,612,433 | 103,832,803 | 26,566,850 | 109,375,722 |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| សមតុល្យនៅធនាគារ | 5 | 3,818,524 | 15,480,296 | 3,773,687 | 15,536,269 |
| ទ្រព្យ និងបរិក្ខារ | 8 | 7,059,916 | 28,620,899 | 7,007,931 | 28,851,652 |
| ទ្រព្យសកម្មអរូបី | 9 | 255,408 | 1,035,424 | 259,621 | 1,068,860 |
| | | 11,133,848 | 45,136,619 | 11,041,239 | 45,456,781 |
| **ទ្រព្យសកម្មសរុប** | | 36,746,281 | 148,969,422 | 37,608,089 | 154,832,503 |
| **បំណុល និងមូលធន** | | | | | |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | 10 | 1,730,362 | 7,014,888 | 3,741,073 | 15,401,998 |
| ប្រាក់កម្ចី | 11 | 1,826,746 | 7,405,628 | 1,782,400 | 7,338,141 |
| មូលបត្របំណុល | 12 | 881,427 | 3,573,305 | 233,763 | 962,402 |
| បំណុលលើអត្ថប្រយោជន៍និយោជិត | 13 | 51,304 | 207,986 | 86,391 | 355,672 |
| បំណុលពន្ធអប្បបរមា | 20(ខ) | 11,212 | 45,453 | 66,007 | 271,751 |
| | | 4,501,051 | 18,247,260 | 5,909,634 | 24,329,964 |

# រ៉ូយ៉ាល់ គ្រុបភ្នំពេញ ម.ក.

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## នាថ្ងៃទី31 ខែមីនា ឆ្នាំ2023

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 ដុល្លារអាមេរិក | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 ពាន់រៀល (កំណត់សម្គាល់ 4) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| **បំណុលរយៈពេលវែង** | | | | | |
| មូលបត្របំណុល | 12 | 33,051,243 | 133,989,739 | 33,051,243 | 136,071,967 |
| ប្រាក់កម្ចី | 11 | 786,152 | 3,187,060 | 855,227 | 3,520,970 |
| បំណុលលើអត្ថប្រយោជន៍និយោជិត | 13 | 52,494 | 212,811 | 61,693 | 253,990 |
| | | 33,889,889 | 137,389,610 | 33,968,163 | 139,846,927 |
| **បំណុលសរុប** | | 38,390,940 | 155,636,870 | 39,877,797 | 164,176,891 |
| **មូលធន** | | | | | |
| ដើមទុន | 14 | 13,020,930 | 52,083,720 | 13,020,930 | 52,083,720 |
| ប្រាក់ខាតបង្គរ | | (14,665,589) | (59,664,961) | (15,290,638) | (62,217,661) |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 913,793 | - | 789,553 |
| | | (1,644,659) | (6,667,448) | (2,269,708) | (9,344,388) |
| **បំណុល និងមូលធនសរុប** | | 36,746,281 | 148,969,422 | 37,608,089 | 154,832,503 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ អេលចេ ម.ក.

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

| | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| ចំណូល | 15 | 2,694,507 | 11,004,367 | 2,976,081 | 12,091,817 |
| ថ្លៃដើមសេវាកម្ម | 16 | (3,078,272) | (12,571,663) | (2,981,978) | (12,115,777) |
| **ប្រាក់ខាតដុល** | | (383,765) | (1,567,296) | (5,897) | (23,960) |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 17 | 423,892 | 1,731,175 | 154,820 | 629,034 |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | 18 | 1,277,513 | 5,217,363 | (456,469) | (1,854,634) |
| ការកត់ត្រឡប់វិញ/(សំវិធានធន) សម្រាប់ការខាតបង់ឱនភាពនៃតម្លៃ | 5,6 | 20,214 | 82,554 | (10,960) | (44,530) |
| ចំណាយពន្ធអប្បបរមា | 20(គ) | (31,042) | (126,776) | (31,382) | (127,505) |
| **ប្រាក់ចំណេញ/(ប្រាក់ខាត) ពីប្រតិបត្តិការ** | | 1,306,812 | 5,337,020 | (349,888) | (1,421,595) |
| ចំណាយហិរញ្ញប្បទាន | 21 | (681,763) | (2,784,320) | (32,930) | (133,795) |
| **ប្រាក់ចំណេញ/(ខាត) មុនដកពន្ធលើ ប្រាក់ចំណេញ** | | 625,049 | 2,552,700 | (382,818) | (1,555,390) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(គ) | - | - | - | - |
| **ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 625,049 | 2,552,700 | (382,818) | (1,555,390) |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | |
| **ធាតុដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញ ក្នុងរបាយការណ៍ចំណេញ ឬខាត** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 124,240 | - | (39,396) |
| **ប្រាក់ចំណេញ/(ប្រាក់ខាត) លម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | 625,049 | 2,676,940 | (382,818) | (1,594,786) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ អេលអេ ម.ក.

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

| | ដើមទុន | | ប្រាក់ខាតបង្គរ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 13,020,930 | 52,083,720 | (15,290,638) | (62,217,661) | - | 789,553 | (2,269,708) | (9,344,388) |
| ***លទ្ធផលលម្អិតសរុប*** | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 625,049 | 2,552,700 | - | - | 625,049 | 2,552,700 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 124,240 | - | 124,240 |
| | - | - | 625,049 | 2,552,700 | - | 124,240 | 625,049 | 2,676,940 |
| ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | 13,020,930 | 52,083,720 | (14,665,589) | (59,664,961) | - | 913,793 | (1,644,659) | (6,667,448) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2022 | 13,020,930 | 52,083,720 | (11,172,067) | (45,385,061) | - | 833,609 | 1,848,863 | 7,532,268 |
| ***លទ្ធផលលម្អិតសរុប*** | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ *(មិនត្រូវបានត្រួតពិនិត្យ)* | - | - | (382,818) | (1,555,390) | - | - | (382,818) | (1,555,390) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (39,396) | - | (39,396) |
| | - | - | (382,818) | (1,555,390) | - | (39,396) | (382,818) | (1,594,786) |
| ថ្ងៃទី31 ខែមីនា ឆ្នាំ2022 *(មិនត្រូវបានត្រួតពិនិត្យ)* | 13,020,930 | 52,083,720 | (11,554,885) | (46,940,451) | - | 794,213 | 1,466,045 | 5,937,482 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

## រ៉ូយ៉ាល់ គ្រុបភ្នំពេញ ម.ក.

# របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
# សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញ/(ខាត)សុទ្ធ | | | | |
| សម្រាប់ការិយបរិច្ឆេទ | 625,049 | 2,552,700 | (382,818) | (1,555,390) |
| និយ័តភាពលើ៖ | | | | |
| រំលស់ | 300,652 | 1,227,863 | 238,726 | 969,944 |
| ចំណាយហិរញ្ញប្បទាន | 681,763 | 2,784,320 | 32,930 | 133,795 |
| អត្ថប្រយោជន៍និយោជិត | 50,256 | 205,246 | 51,347 | 208,623 |
| ការលុបចោលទ្រព្យ និងបរិក្ខារ | 346 | 1,413 | - | - |
| ចំណាយពន្ធអប្បបរមា | 31,042 | 126,776 | 31,382 | 127,505 |
| ការកត់ត្រឡប់មកវិញសម្រាប់បំណុល | | | | |
| ពន្ធអប្បរមា | (57,429) | (234,540) | - | - |
| (ការកត់ត្រឡប់មកវិញ)/សំវិធានធន | | | | |
| សម្រាប់ការខាតបង់ឱនភាពនៃតម្លៃ | (20,214) | (82,554) | 10,960 | 44,530 |
| | 1,611,465 | 6,581,224 | (17,473) | (70,993) |
| បម្រែបម្រួលនៃ៖ | | | | |
| គណនីអតិថិជន | | | | |
| និងគណនីត្រូវទទួលផ្សេងៗ | (389,302) | (1,589,909) | (561,931) | (2,283,126) |
| សន្និធិ | (68,306) | (278,962) | (21,289) | (86,497) |
| គណនីអ្នកផ្គត់ផ្គង់ | | | | |
| និងគណនីត្រូវទូទាត់ផ្សេងៗ | (2,015,423) | (8,230,988) | 584,741 | 2,375,803 |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | (861,566) | (3,518,635) | (15,952) | (64,813) |
| ការប្រាក់បានបង់ | (26,385) | (107,756) | (32,930) | (133,795) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | (94,542) | (386,110) | (71,108) | (288,912) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (28,408) | (116,018) | (31,093) | (126,331) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (1,010,901) | (4,128,519) | (151,083) | (613,851) |

# រ៉ូយ៉ាល់ គ្រុប ភ.ក.

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

| | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (348,770) | (1,424,377) | (132,058) | (536,552) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ | (348,770) | (1,424,377) | (132,058) | (536,552) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | - | - | 500,000 | 2,031,500 |
| ការទូទាត់ប្រាក់កម្ចី | (27,731) | (113,253) | (206,751) | (840,029) |
| សាច់ប្រាក់ដាក់ក្នុងគណនីបម្រុង | (44,837) | (183,114) | - | - |
| សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពី សកម្មភាពហិរញ្ញប្បទាន | (72,568) | (296,367) | 293,249 | 1,191,471 |
| **(ការថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (1,432,239) | (5,849,263) | 10,108 | 41,068 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | 24,191,824 | 99,597,739 | 121,766 | 496,075 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (1,481,119) | - | (3,053) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** (កំណត់សម្គាល់ 5) | 22,759,585 | 92,267,357 | 131,874 | 534,090 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## 1. ព័ត៌មានទូទៅ

រ៉ូយ៉ាល់ រេលវេ ម.ក. ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនត្រូវបានបង្កើតឡើងដំបូង ក្រោមលេខបញ្ជីពាណិជ្ជកម្ម Co. 2874/06E ចុះថ្ងៃទី6 ខែមេសា ឆ្នាំ2006 ចេញដោយក្រសួងពាណិជ្ជកម្ម។ បន្ទាប់មកក្រុមហ៊ុនបានទទួលការអនុម័តពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីក្លាយជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ("QIP") ដែលមានលេខចុះបញ្ជីថ្មី 0643KH/2014 ចុះថ្ងៃទី6 ខែតុលា ឆ្នាំ2015។ នៅថ្ងៃទី25 ខែសីហា ឆ្នាំ2016 ក្រុមហ៊ុនបានចុះបញ្ជីឡើងវិញ និងទទួលលេខបញ្ជីពាណិជ្ជកម្មថ្មីគឺ 00018504 ពីក្រសួងពាណិជ្ជកម្ម។

ក្រុមហ៊ុនដំណើរការសេវាកម្មផ្លូវដែកក្រោម កិច្ចព្រមព្រៀងសម្បទានផ្លូវដែក ("កិច្ចព្រមព្រៀងសម្បទាន") ជាមួយរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីផ្តល់សេវាកម្មផ្លូវដែកនៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល 30ឆ្នាំ ទៅលើទ្រព្យសកម្មសម្បទានជាក់លាក់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។ ប៉ុន្តែកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងសម្បទាន គឺមិនទាន់បានកំណត់ជាផ្លូវការនោះទេ ដោយសារតែលក្ខខណ្ឌមុនកាលបរិច្ឆេទចូលជាធរមាននៅពុំទាន់បានបំពេញទាំងស្រុងនៅឡើយ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុននៅតែបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសម្បទានផ្លូវដែកថ្មី។

ភាគហ៊ុនរបស់ក្រុមហ៊ុន 98.9999% ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) និង 1.0001% ទៀតជាកម្មសិទ្ធិរបស់អ្នកឧកញ៉ា គិត ម៉េង។

ការិយាល័យដែលបានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅស្ថានីយ៍ផ្លូវដែកកណ្តាល មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នាថ្ងៃទី31 ខែមីនា ឆ្នាំ2023 ក្រុមហ៊ុនមានបុគ្គលិកចំនួន 812 នាក់ (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ មានបុគ្គលិកចំនួន 717 នាក់)។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

## 2. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 34 *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"* ។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលនូវរាល់ព័ត៌មានទាំងស្រុងរបស់របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានោះទេ។ យ៉ាងណាមិញ កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើស ត្រូវបានដាក់បញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលមានលក្ខណៈជាសារវន្ត ក្នុងការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុនចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយនាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី15 ខែឧសភា ឆ្នាំ2023។

### (ខ) គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

### (គ) ការសន្មតនិរន្តរភាពអាជីវកម្ម

នៅក្នុងដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023 ក្រុមហ៊ុនបង្កើតប្រាក់ចំណេញសុទ្ធចំនួន 625,049 ដុល្លារអាមេរិក (ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022: ប្រាក់ខាតសុទ្ធចំនួន 382,818 ដុល្លារអាមេរិក) និងបង្កើតសាច់ប្រាក់អវិជ្ជមានពីសកម្មភាពប្រតិបត្តិការសុទ្ធចំនួន 1,010,901 ដុល្លារអាមេរិក (ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022: 151,083 ដុល្លារអាមេរិក) ហើយគិតត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2023 ក្រុមហ៊ុនមានប្រាក់ខាតបង្គរចំនួន 14,665,589 ដុល្លារអាមេរិក (ថ្ងៃទី31 ខែមីនា ឆ្នាំ2022៖ 15,290,638 ដុល្លារអាមេរិក)។

## រ៉ូយ៉ាល់ គេលទេ ម.ក.

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023**

### 2. មូលដ្ឋាននៃការរៀបចំ (ត)

### (គ) ការសន្មតនិរន្តរភាពអាជីវកម្ម (ត)

សុពលភាពនៃការសន្មតនិរន្តភាពអាជីវកម្មជាមូលដ្ឋាន គឺអាស្រ័យទៅលើការបន្តផ្តល់ជំនួយហិរញ្ញវត្ថុរបស់ភាគទុនិកធំដែលចាំបាច់ដើម្បីឲ្យក្រុមហ៊ុនអាចមានលទ្ធភាពក្នុងការទូទាត់បំណុលរបស់ខ្លួន នៅពេលដល់កំណត់ដែលត្រូវទូទាត់សង និងដើម្បីរក្សានិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុននាពេលអនាគត។ នាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ភាគទុនិកបានបញ្ជាក់ពីការគាំទ្រផ្នែកហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់បន្តទៀតដល់ក្រុមហ៊ុន ហើយពុំមានហេតុផលណាមួយដែលអាចឲ្យអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនជឿជាក់ថា ភាគទុនិកនឹងមិនបន្តការគាំទ្រដល់ក្រុមហ៊ុននោះទេ។

### (ឃ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ អ្នកគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែង អាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ប្រមាណត្រូវបានទទួលស្គាល់តាមវិធីសាស្រ្តទស្សនវិស័យ។

### 3. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលទាំងនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ចំនួនទាំងអស់ត្រូវបានបង្គត់ទៅដុល្លារអាមេរិកដែលនៅជិតបំផុត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

### 4. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះ ធ្វើឡើងដោយអនុលោមទៅតាមស.គ.អ .ក 21 – ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យម នៅក្នុងការិយបរិច្ឆេទរាយការណ៍ ដែលអត្រានេះត្រូវបានចាត់ទុកថាមានកម្រិតប្រហាក់ប្រហែលទៅនឹងអត្រាប្តូររូបិយប័ណ្ណនាថ្ងៃប្រតិបត្តិការ ដោយសារតែអត្រាប្តូររូបិយប័ណ្ណ មិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែល កើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| **ការិយបរិច្ឆេទហិរញ្ញវត្ថុ** | | **អត្រានាកាល បរិច្ឆេទរាយការណ៍** | **អត្រាមធ្យម ការិយបរិច្ឆេទ 3ខែ** |
|---|---|---|---|
| ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | 1 ដុល្លារអាមេរិក= | 4,054 រៀល | 4,084 រៀល |
| ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | 1 ដុល្លារអាមេរិក= | 4,050 រៀល | 4,063 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 1 ដុល្លារអាមេរិក= | 4,117 រៀល | មិនមាន |

ការកែសម្រួលនេះ មិនគួរត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

## 5. សាច់ប្រាក់ និងសមតុល្យនៅធនាគារ

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| *រយៈពេលខ្លី* | | | | |
| សាច់ប្រាក់ក្នុងដៃ | 3,526 | 14,294 | 5,538 | 22,800 |
| សាច់ប្រាក់ក្នុងធនាគារ | 22,756,059 | 92,253,063 | 24,186,286 | 99,574,939 |
| សាច់ប្រាក់ និងសមតុល្យ នៅធនាគារសរុប | 22,759,585 | 92,267,357 | 24,191,824 | 99,597,739 |
| ដកៈ សំវិធានធនលើឱនភាពនៃតម្លៃ | (197,058) | (798,873) | (210,527) | (866,739) |
| | 22,562,527 | 91,468,484 | 23,981,297 | 98,731,000 |
| *រយៈពេលវែង* | | | | |
| សាច់ប្រាក់ក្នុងធនាគារៈ | | | | |
| គណនីបម្រុងសេវាបំណុល ("DSRA") * | 3,464,274 | 14,044,166 | 3,423,595 | 14,094,940 |
| គណនីបម្រុងសេវាធានា ("GFRA") * | 354,250 | 1,436,130 | 350,092 | 1,441,329 |
| សមតុល្យនៅធនាគារសរុប | 3,818,524 | 15,480,296 | 3,773,687 | 15,536,269 |

* គណនីបម្រុងសេវាបំណុល និងគណនីបម្រុងសេវាធានា គឺជាគណនីបម្រុងដែលបានកំណត់សម្រាប់ការទូទាត់បំណុល និងការទូទាត់ថ្លៃសេវាធានា ក្នុងករណីមានការខកខាននៃលំហូរទឹកប្រាក់សម្រាប់ទូទាត់លើមូលបត្របំណុលហើយវាត្រូវបានរក្សាទុកនៅធនាគារអេស៊ីលីដា ដែលទទួលបានការប្រាក់ក្នុងអត្រា 5.00%ក្នុងមួយឆ្នាំ (2022៖ មិនមាន)។

## 5. សាច់ប្រាក់ និងសមតុល្យនៅធនាគារ (ត)

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| *រយៈពេលខ្លី* | | | | |
| សាច់ប្រាក់ក្នុងដៃ | 3,526 | 14,294 | 5,730 | 23,207 |
| សាច់ប្រាក់ក្នុងធនាគារ | 22,756,059 | 92,253,063 | 126,144 | 510,883 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 22,759,585 | 92,267,357 | 131,874 | 534,090 |
| ដកៈ សំវិធានធនលើឱនភាពនៃតម្លៃ | (197,058) | (798,873) | (1,399) | (5,665) |
| | 22,562,527 | 91,468,484 | 130,475 | 528,425 |

បម្រែបម្រួលនៃសំវិធានធនលើឱនភាពនៃតម្លៃសម្រាប់សមតុល្យនៅធនាគារក្នុងអំឡុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| សមតុល្យដើមការិយបរិច្ឆេទ | (210,527) | (866,739) | - | - |
| ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត | 13,469 | 55,007 | (1,399) | (5,684) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 12,859 | - | 19 |
| សមតុល្យចុងការិយបរិច្ឆេទ | (197,058) | (798,873) | (1,399) | (5,665) |

## រ៉ូយ៉ាល់ រេលវេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

### 6. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| គណនីអតិថិជន | 727,014 | 2,947,315 | 545,610 | 2,246,276 |
| ដកៈ សំវិធានធនលើឱនភាពនៃតម្លៃ | (94,427) | (382,807) | (101,172) | (416,525) |
| | 632,587 | 2,564,508 | 444,438 | 1,829,751 |
| បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | 1,922,349 | 7,793,203 | 1,696,781 | 6,985,647 |
| គណនីត្រូវទទួលពីសម្ព័ន្ធញាតិ (កំណត់សម្គាល់ 22) | 50,650 | 205,335 | 53,094 | 218,588 |
| ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ | 2,605,586 | 10,563,046 | 2,194,313 | 9,033,986 |
| ប្រាក់កក់ | 71,498 | 289,853 | 71,498 | 294,357 |
| ប្រាក់បង់មុន | 32,636 | 132,306 | 32,207 | 132,596 |
| ផ្សេងៗ | 57,045 | 231,260 | 72,700 | 299,307 |
| | 2,766,765 | 11,216,465 | 2,370,718 | 9,760,246 |

បម្រែបម្រួលនៃសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គណនីអតិថិជនក្នុងអំឡុងការិយបរិច្ឆេទ មានដូចខាងក្រោមៈ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) *(មិនត្រូវបានត្រួតពិនិត្យ)* |
| សមតុល្យដើមការិយបរិច្ឆេទ | (101,172) | (416,525) | (82,013) | (334,121) |
| ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត | 6,745 | 27,547 | (9,561) | (38,846) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 6,171 | - | 2,092 |
| សមតុល្យចុងការិយបរិច្ឆេទ | (94,427) | (382,807) | (91,574) | (370,875) |

# រ៉ូយ៉ាល់ គ្រុប ភ្នំពេញ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

## 7. សន្និធិ

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| សម្ភារៈសម្រាប់ជួសជុលក្បាលរថភ្លើង | 81,601 | 330,810 | 62,812 | 258,597 |
| ឧបករណ៍ | 54,502 | 220,952 | 62,641 | 257,893 |
| ប្រេងឥន្ធនៈ | 13,188 | 53,464 | 12,292 | 50,606 |
| ប្រេងម៉ាស៊ូត | 35,812 | 145,182 | 51,257 | 211,025 |
| សម្ភារៈសម្រាប់ជួសជុលទូររថភ្លើង | 98,038 | 397,446 | 25,833 | 106,355 |
| | 283,141 | 1,147,854 | 214,835 | 884,476 |

## 8. ទ្រព្យ និងបរិក្ខារ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023 | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ការកែលម្អ ផ្លូវដែក និងស្ថានីយ៍ | ក្បាលរថភ្លើង | ទូរថភ្លើង | ផ្លូវរថភ្លើង | ត្រូឡេ | បរិក្ខារ និង គ្រឿងម៉ាស៊ីន | បរិក្ខារ ការិយាល័យ | គ្រឿងសង្ហារិម និង គ្រឿងបំពាក់ | បរិក្ខារ ព័ត៌មានវិទ្យា | ស្លាកសញ្ញា និងរបាំងផ្លូវ រថភ្លើង | ទ្រព្យកំពុងបង្កើត | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | | | | | | | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 656,825 | 7,806,896 | 1,211,498 | 580,845 | 32,163 | 736,078 | 9,134 | 8,794 | 97,661 | 15,057 | 160,672 | 11,315,623 | 46,586,419 |
| ការទិញបន្ថែម | - | 241,470 | - | 4,741 | - | 11,469 | - | - | 1,314 | - | 89,776 | 348,770 | 1,424,377 |
| ការផ្ទេរ | 22,425 | - | - | 51,955 | - | - | - | - | - | - | (74,380) | - | - |
| ការលុបចោល | - | - | - | - | - | - | - | - | - | - | (346) | (346) | (1,413) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | (723,337) |
| សមតុល្យចុងការិយបរិច្ឆេទ | 679,250 | 8,048,366 | 1,211,498 | 637,541 | 32,163 | 747,547 | 9,134 | 8,794 | 98,975 | 15,057 | 175,722 | 11,664,047 | 47,286,046 |
| ដកៈ **រំលស់បង្គរ** | | | | | | | | | | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 493,849 | 2,058,562 | 717,830 | 281,832 | 32,163 | 625,441 | 8,135 | 8,794 | 72,868 | 8,218 | - | 4,307,692 | 17,734,767 |
| រំលស់ក្នុងការិយបរិច្ឆេទ | 19,833 | 177,434 | 42,840 | 31,824 | - | 20,379 | 192 | - | 3,184 | 753 | - | 296,439 | 1,210,657 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | (280,277) |
| សមតុល្យចុងការិយបរិច្ឆេទ | 513,682 | 2,235,996 | 760,670 | 313,656 | 32,163 | 645,820 | 8,327 | 8,794 | 76,052 | 8,971 | - | 4,604,131 | 18,665,147 |
| **តម្លៃយោង** | | | | | | | | | | | | | |
| សមតុល្យចុងការិយបរិច្ឆេទ | 165,568 | 5,812,370 | 450,828 | 323,885 | - | 101,727 | 807 | - | 22,923 | 6,086 | 175,722 | 7,059,916 | 28,620,899 |

គិតត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2023 ទ្រព្យ និងបរិក្ខារ ដែលបានរំលស់ពេញលេញ និងមានថ្លៃដើមចំនួន 60,549 ដុល្លារអាមេរិក (ថ្ងៃទី31 ខែមីនា ឆ្នាំ2022៖ ចំនួន 1,100,361 ដុល្លារអាមេរិក – មិនត្រូវបានត្រួតពិនិត្យ) គឺនៅតែបន្តប្រើប្រាស់នៅឡើយ។

## រ៉ូយ៉ាល់ រេលវេ ម.ក.

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2023

### 8. ទ្រព្យ និងបរិក្ខារ (ត)

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | | | | | | | | | | | |
